ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ៣៦៤៤ ព.ណ.អ.ស.ដ

ក្រសួងមហាផ្ទៃ

សេចក្តីណែនាំអន្តរក្រសួង
ស្តីពី
ការអនុវត្តមុខងារអភិវឌ្ឍន៍មូលដ្ឋានក្នុងវិស័យពាណិជ្ជកម្ម
នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍមូលដ្ឋានស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យលេខ១៨២ ១៨៣ និង១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក និងខណ្ឌនៃរដ្ឋបាលរាជធានីភ្នំពេញ អនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ និងអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម មុខងារអភិវឌ្ឍន៍មូលដ្ឋានចំនួនពីរក្នុងវិស័យពាណិជ្ជកម្ម ត្រូវបានប្រគល់ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមាន៖

ក- ការងារបិទស្លាកថ្លៃលើមុខទំនិញ៖ ការត្រួតពិនិត្យលើការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាគ្រប់ប្រភេទ និងការស្រង់សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពប្រចាំថ្ងៃ

ខ- ការងារទីផ្សារ៖ ការស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់ប្រជាពលរដ្ឋ។

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តមុខងារអភិវឌ្ឍន៍មូលដ្ឋានក្នុងវិស័យពាណិជ្ជកម្មនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រសួងពាណិជ្ជកម្ម និងក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដូចខាងក្រោម៖

ក. ការងារបិទស្លាកថ្លៃលើមុខទំនិញ

១. ការត្រួតពិនិត្យលើការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាគ្រប់ប្រភេទ

១.១. គោលការណ៍

- អនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម រាល់អាជីវករ ពាណិជ្ជករ និង/ឬ សេវាករ ត្រូវបិទស្លាកថ្លៃជាប្រាក់រៀល និងលក្ខខណ្ឌនៃការលក់ដូរដែលនៅជាធរមាន បែបបទនៃការបិទផ្សាយ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម លើកលែងតែទីតាំងប្រកបអាជីវកម្មទំនិញរួចពន្ធ (Duty Free) ដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ត្រូវស្នើសុំការបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេស
- អាជីវករ សេវាករ ពាណិជ្ជករ ត្រូវបិទស្លាកថ្លៃលើគ្រប់មុខទំនិញ និងសេវា ដោយប្រើប្រាស់សម្ភារមធ្យោបាយ ឬវិធីផ្សេងទៀត ដើម្បីឱ្យអតិថិជនងាយស្រួលមើល និងមិនភ័ន្តច្រឡំ

១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ contact@moc.gov.kh

- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវត្រួតពិនិត្យការបិទស្លាកថ្លៃលើមុខទំនិញនិងសេវាគ្រប់ប្រភេទ។ ក្នុងករណីអាជីវករ ពាណិជ្ជករ និង/ឬសេវាករមិនអនុវត្តការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្ម របស់ខ្លួន រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់វិធានការដូចខាងក្រោម៖
  ក- ធ្វើការអប់រំណែនាំ
  ខ- ធ្វើលិខិតព្រមានជាលាយលក្ខណ៍អក្សរ។

១.២. នីតិវិធីនៃការអនុវត្តមុខងារ

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តការងារមួយចំនួន ដូចខាងក្រោម៖

- ធ្វើផែនការសកម្មភាពប្រចាំឆ្នាំ សម្រាប់ការចុះផ្សព្វផ្សាយ និងការចុះត្រួតពិនិត្យមើលការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្ម
- រៀបចំឱ្យមានការផ្សព្វផ្សាយជាលក្ខណៈប្រមូលផ្តុំ និង/ឬការចុះដល់ទីតាំងអាជីវកម្មផ្ទាល់
- ចុះត្រួតពិនិត្យមើលប្រចាំខែ ការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មនៅតាមទីតាំងអាជីវកម្ម ក្នុងមូលដ្ឋានរបស់ខ្លួន ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ។

២. ការស្រង់សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពប្រចាំថ្ងៃ

២.១. គោលការណ៍

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវស្រង់សន្ទស្សន៍ថ្លៃទំនិញចាំបាច់ដែលប្រជាពលរដ្ឋមានតម្រូវការប្រើប្រាស់ជាប្រចាំ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធភ្ជាប់នឹងសេចក្តីណែនាំអន្តរក្រសួងនេះ នៅតាមទីតាំង ឬទីផ្សារសំខាន់ៗ ដែលកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងជានានូវស្ថិរភាពថ្លៃទំនិញក្នុងភូមិសាស្ត្ររបស់ខ្លួន។

ដើម្បីជានាបាននូវស្ថិរភាពថ្លៃទំនិញនៅតាមទីផ្សារក្នុងភូមិសាស្ត្ររបស់ខ្លួន រដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗ ត្រូវចាត់ចែងស្រង់សន្ទស្សន៍ថ្លៃទំនិញ និងសេវាចាំបាច់ប្រចាំថ្ងៃដូចខាងក្រោម៖

- ស្រង់ថ្លៃទំនិញធ្វើឡើងរៀងរាល់ថ្ងៃនៃថ្ងៃធ្វើការ និងតាមការចាំបាច់នៅតាមទីតាំង ឬទីផ្សារសំខាន់ៗ ដែលត្រូវបានកំណត់ដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយសហការជាមួយគណៈកម្មការ ឬប្រធានផ្សារ (រដ្ឋ និងឯកជន)
- តម្លៃទំនិញលក់រាយ ត្រូវបានស្រង់នៅលើទីផ្សារក្រុង ស្រុក ខណ្ឌនានាទូទាំងប្រទេស តាមការកំណត់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សាមី។ (ដូចមានគំរូជូនភ្ជាប់)

២.២. នីតិវិធីនៃការអនុវត្តមុខងារ

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់មន្ត្រីជំនាញនៃការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ឱ្យស្រង់សន្ទស្សន៍ និងវិភាគថ្លៃទំនិញក្នុងមូលដ្ឋានរបស់ខ្លួន ដោយត្រូវអនុវត្តការងារដូចខាងក្រោម៖

- មន្ត្រីទទួលបន្ទុកត្រូវសហការជាមួយគណៈកម្មការ ឬប្រធានផ្សារ (រដ្ឋ និងឯកជន) ស្រង់សន្ទស្សន៍ និងវិភាគថ្លៃទំនិញរៀងរាល់ថ្ងៃនៃថ្ងៃធ្វើការ និងតាមការចាំបាច់នៅតាមផ្សារគោលដៅក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាននៅក្នុងមូលដ្ឋានសាមីនីមួយៗ
- មន្ត្រីទទួលបន្ទុកត្រូវរៀបចំបញ្ចូលទិន្នន័យក្នុងតារាងថ្លៃទំនិញប្រចាំថ្ងៃ និងបញ្ជូនតារាងនេះមកមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រឹមម៉ោង១០ព្រឹក

- មន្ត្រីទទួលបន្ទុកត្រូវបូកថ្លៃទំនិញ (១) និងរកថ្លៃទំនិញជាមធ្យមភាគប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីធ្វើការតាមដាន និងស្វែងយល់អំពីការវិវត្តថ្លៃទំនិញទាំងនោះក្នុងមូលដ្ឋានរបស់ខ្លួន
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ចែងផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋនូវតារាងថ្លៃទំនិញប្រចាំថ្ងៃនេះ តាមគ្រប់មធ្យោបាយ។

ខ. ការស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់ប្រជាពលរដ្ឋ

ខ.១. គោលការណ៍

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវដើរតួនាទីយ៉ាងសកម្មជាអ្នកសម្របសម្រួល និងជាស្ពានតភ្ជាប់ទំនាក់ទំនងរវាងអ្នកផលិត (ប្រជាពលរដ្ឋ កសិករ សិប្បករ) និងទីផ្សារ (អ្នកប្រមូលទិញ ឈ្មួញ ក្រុមហ៊ុន) ដោយត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការស្វែងរក និងពង្រីកទីផ្សារជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន៖

- ផ្តល់ព័ត៌មានទីផ្សារ ការសម្របសម្រួលការទិញលក់ និងការទាក់ទាញការវិនិយោគ ត្រូវធ្វើឡើងដោយតម្លាភាព សមធម៌ និងគ្មានការរើសអើង ដើម្បីធានាថាប្រជាពលរដ្ឋ និងអ្នកផលិតនៅមូលដ្ឋានទទួលបានឱកាសស្មើៗគ្នា
- លើកកម្ពស់កិច្ចសហការជិតស្និទ្ធជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធ វិស័យឯកជន សភាពាណិជ្ជកម្ម និងភាគីពាក់ព័ន្ធផ្សេងៗទៀត ដើម្បីកៀរគរធនធាន ចែករំលែកព័ត៌មាន និងពង្រីកឱកាសទីផ្សារឱ្យបានទូលំទូលាយ
- ចូលរួមជំរុញ ណែនាំ និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យផលិតកសិផល ឬផលិតផលនានាដែលមានគុណភាព សុវត្ថិភាព និងស្របតាមតម្រូវការជាក់ស្តែងរបស់ទីផ្សារ ជាជាងការផលិតតាមទម្លាប់ដែលគ្មានទីផ្សារច្បាស់លាស់។

ខ.២. នីតិវិធីនៃការអនុវត្តមុខងារ

ដើម្បីស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់ប្រជាពលរដ្ឋ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តការងារមួយចំនួនដូចខាងក្រោម៖

- ចុះស្រង់ព័ត៌មានអំពីកសិផល កសិ-ឧស្សាហកម្ម និងផលិតផលសក្តានុពលមួយចំនួនដែលដាំដុះ និងផលិតនៅក្នុងក្រុង ស្រុក ខណ្ឌរបស់ខ្លួន
- ផ្សព្វផ្សាយព័ត៌មានអំពីតម្រូវការផលិតផលក្នុងទីផ្សារដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- ស្វែងរកទីផ្សារ និងកៀរគរការចូលរួមវិនិយោគពីវិស័យឯកជននិងវិស័យសាធារណៈ និងភាគីពាក់ព័ន្ធដទៃទៀតសម្រាប់ផលិតផលដែលផលិតបាន
- ប្រមូលទិន្នន័យចំនួនផ្សារ (រដ្ឋ ឯកជន ទំនើប ម៉ាត មីនីម៉ាត ផ្សាររាត្រី ផ្សារសហគមន៍)ដែលមានក្នុងមូលដ្ឋានក្រុង ស្រុក ខណ្ឌ
- ចូលរួមសម្របសម្រួល ផ្តល់ព័ត៌មានទីផ្សារដល់ប្រជាពលរដ្ឋ និងដោះស្រាយបញ្ហានានា ពាក់ព័ន្ធនឹងទីផ្សារសម្រាប់ផលិតផលរបស់ប្រជាពលរដ្ឋ
- ក្នុងករណីមានការកកស្ទះផលិតផល និងមិនអាចដោះស្រាយបាននៅមូលដ្ឋាន រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់វិធានការជាបន្ទាន់ដោយលើកសំណើមកមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដើម្បី

សម្របសម្រួលដោះស្រាយនិងក្នុងករណីមិនអាចដោះស្រាយបាន ត្រូវរាយការណ៍ជូនរដ្ឋបាលរាជធានី ខេត្ត និងក្រសួងពាណិជ្ជកម្ម ដើម្បីស្នើសុំកិច្ចអន្តរាគមន៍។

គ. ការតាមដាន ការវាយតម្លៃ និងការគាំទ្រការអនុវត្តមុខងារ

រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវផ្តល់ការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ ចំពោះការអនុវត្តមុខងារអភិវឌ្ឍន៍មូលដ្ឋានក្នុងវិស័យពាណិជ្ជកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ឃ. របាយការណ៍

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ជាទៀងទាត់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តមុខងារអភិវឌ្ឍន៍មូលដ្ឋានក្នុងវិស័យពាណិជ្ជកម្មជូនមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដើម្បីធ្វើការបូកសរុបនិងរាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងតាមការចាំបាច់មកក្រសួងពាណិជ្ជកម្មដោយត្រូវចម្លងជូនក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី ខេត្តសាមី។

ទទួលបានសេចក្តីណែនាំអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីណែនាំនេះឱ្យបានទូលំទូលាយ និងត្រូវទទួលបន្ទុកអនុវត្តឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣រោច ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ២០២៦

រដ្ឋមន្ត្រី	**ឧបនាយករដ្ឋមន្ត្រី**
ក្រសួងពាណិជ្ជកម្ម	**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
ចម និម្មល	**អភិសន្តិបណ្ឌិត ស សុខា**

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ

រាជធានី/ខេត្ត.....

រដ្ឋបាលក្រុង ស្រុក ខណ្ឌ.....

លេខ:

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
****

កម្មវត្ថុ ៖ របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពចំនួន ៦៤មុខ នៅក្រុង ស្រុក ខណ្ឌ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម លោក/លោកស្រីប្រធាន មេត្តាជ្រាបពីសន្ទស្សន៍នៃមុខទំនិញចាំបាច់ប្រចាំជីវភាពថ្ងៃទី.....ខែ.....ឆ្នាំ២០..... ដូចតារាងខាងក្រោម៖

ល.រ	ប្រភេទទំនិញ	មុខទំនិញ	ឯកតា	ថ្លៃគ្រាគោល(រៀល)			ថ្លៃប្រមូលប្រចាំថ្ងៃ (រៀល)	ភាគរយ			ថ្លៃប្រមូលប្រចាំថ្ងៃនៅតាមផ្សារ (រៀល)		
				ថ្ងៃទី១ ខែមករា ឆ្នាំ២០២៦	ថ្ងៃដូចគ្នា នៃខែមុន ថ្ងៃទី១៥ខែមេសា ឆ្នាំ២០២៦	ថ្ងៃ និងខែដូចគ្នា នៃឆ្នាំមុន ថ្ងៃទី១៥ខែមេសា ឆ្នាំ២០២៥	ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៦	ធៀបនឹងថ្លៃគ្រាគោល (ថ្ងៃទី១ ខែមករា ឆ្នាំ ២០២៦)	ធៀបនឹងថ្ងៃដូចគ្នា នៃខែមុន(ថ្ងៃទី១៥ ខែមេសា ឆ្នាំ ២០២៦)	ធៀបនឹងថ្ងៃ និងខែ ដូចគ្នានៃឆ្នាំមុន (ថ្ងៃ ទី១៥ខែឧសភា ឆ្នាំ ២០២៥)	ផ្សារក្រែង ព្រៃវែង	ផ្សារ....	ផ្សារ....
ក្រុមម្ហូបអាហារ													
១	ធញ្ញជាតិ និង ប្រភេទម្សៅ	អង្ករផ្កាម្លិះ ឬប្រហាក់ប្រហែល[1]	១គីឡូ										
២		មីស្ងួតសរសៃវែង, ពណ៌លឿង, ខ្មែរ	១គីឡូ										
៣		មីកញ្ចប់[2]	១កេស										
៤		ម្សៅមីលេខ១[3]	១គីឡូ										
៥	សាច់ និងប្រភពប្រូតេអ៊ីនសត្វ	សាច់មាន់ស្រែ[4]	១គីឡូ										
៦		សាច់មាន់កសិកម្ម [5]	១គីឡូ										
៧		សាច់គោ (សាច់គោស្មាមុខ)[6]	១គីឡូ										
៨		សាច់ជ្រូក (សាច់សុទ្ធ)[7]	១គីឡូ										
៩		សាច់ទា(ទាសំពៅ)	១គីឡូ										
១០		ប្លើមគោ	១គីឡូ										
១១		ប្លើមជ្រូក	១គីឡូ										
១២	ត្រី និងផលិតផលជលផល	ត្រីរ៉ស់ " ស្រស់ "	១គីឡូ										
១៣		ត្រីទីឡាព្យាក្រហម " ស្រស់ "	១គីឡូ										
១៤		ត្រីប្រា " ស្រស់ "	១គីឡូ										
១៥		ត្រីងៀត " ត្រីរ៉ស់ "	១គីឡូ										
១៦		ត្រីឆ្នើរ " ត្រីរៀល "	១ចង្កាក់										
១៧		ត្រីប្រាហើម	១គីឡូ										

១៨		ប្រហុក " សាច់ "	១គីឡូ										
១៩		បង្គា ស្រស់ មធ្យម	១គីឡូ										
២០		មឹក ស្រស់ មធ្យម	១គីឡូ										
២១		ត្រកួន	១គីឡូ										
២២		ត្រសក់[8]	១គីឡូ										
២៣		ស្ពៃបូកគោ	១គីឡូ										
២៤		ស្ពៃក្រញ៉ាញ់[9]	១គីឡូ										
២៥		ស្ពៃក្តោប	១គីឡូ										
២៦		ជើមខាត់ណា	១គីឡូ										
២៧		ផ្កាខាត់ណា (ស)	១គីឡូ										
២៨	បន្លែ	សាឡាត់ខ្មែរ[10]	១គីឡូ										
២៩		ផ្សឺតចំបើង	១គីឡូ										
៣០		ការ៉ុត[11]	១គីឡូ										
៣១		ដំឡូងជ្វា[12]	១គីឡូ										
៣២		ខ្ញីដុំ	១គីឡូ										
៣៣		ក្រូចឆ្មាខ្មែរ [13]	១គីឡូ										
៣៤		ខ្ទឹម ស ខ្មែរ[14]	១គីឡូ										
៣៥		ខ្ទឹមបារាំង	១គីឡូ										
៣៦		ម្នាស់	១ផ្លែ										
៣៧		ចេកណាំវ៉ា	១គីឡូ										
៣៨		ល្អុងខ្ញី[15]	១គីឡូ										
៣៩	ផ្លែឈើ	ស្វាយកែវរមៀត	១គីឡូ										
៤០		ផ្លែស្រកានាគ (សាច់ពណ៌ស)	១គីឡូ										
៤១		ផ្លែប៉ោមក្រហមខ្នាតកណ្តាល (៥-៦ផ្លែ)	១គីឡូ										
៤២	ទឹកដោះគោ	ទឹកដោះគោស្រស់	១លីត្រ										
៤៣	និងស៊ុត	ទឹកដោះគោខាប់ខ្មែរ	១កំប៉ុង										
៤៤		ពងទា[16]	១០គ្រាប់										
ក្រុមមុខទំនិញប្រើប្រាស់ប្រចាំថ្ងៃនៅផ្ទះបាយ													
៤៥	ប្រេង	ប្រេងអូលីវ[17]	1លីត្រ										
៤៦		ប្រេងឆា (ប្រេងសណ្តែកសៀង)	១លីត្រ										
៤៧		ស្ករស	១គីឡូ										
៤៨		ស្ករត្នោត [18]	១គីឡូ										

៤៩	ស្ករ គ្រឿងទេស ទូទៅ និងមុខទំនិញចាំបាច់	អំបិលម៉ត់	១គីឡូ										
៥០		ម្រេចខ្មៅម៉ត់(១០០ក្រាម)	១កញ្ចប់										
៥១		ទឹកត្រី៣០០ម.ល	១ដប										
៥២		ទឹកស៊ីអ៊ីវ៣២០ម.ល	១ដប										
៥៣		ត្រីខកំប៉ុង ១៥៥ក្រាម	១កំប៉ុង										
៥៤		ហ្គាស	២៩,៥លីត្រ										
៥៥		ធ្យូងអនាម័យ	១គីឡូ										
ក្រុមមុខទំនិញប្រើប្រាស់ប្រចាំថ្ងៃផ្សេងៗទៀត													
៥៦	សាប៊ូ	សាប៊ូកក់សក់ក្លិនចំណុះ៣២០ម.ល	១ដប										
៥៧		សាប៊ូដុំដុសខ្លួនromano	១ដុំ										
៥៨		សាប៊ូម្សៅបោកខោអាវខ្លិល ៣គីឡូ	១កញ្ចប់										
៥៩		សាប៊ូលាងចានpower100	១.៣៥លីត្រ										
៦០	ផលិតផលផ្សេងៗទៀត	ថ្នាំដុសធ្មេញ ១៦០ក្រាម	១ទីប										
៦១		កាហ្វេគីឡូកិន	១គីឡូ										
៦២		តែកញ្ចប់(សញ្ញានាគ២)	១កញ្ចប់										
៦៣		ម្សៅទឹកដោះគោទារក Similac ៨០០ក្រាម	១កំប៉ុង										
៦៤		ខោទឹកនោមទារក (Pao Pao) ទំហំ M(២២ខោ)	១ថង់										

[1] តម្លៃខ្ពស់ជាងអង្គរផ្កាខ្ចីប្រមាណ៣០០-៤០០រៀល/គីឡូក្រាម និងខ្ពស់ជាងអង្គរនោងមិញ ឬប្រហាក់ប្រហែលប្រមាណ ៦០០រៀល/គីឡូក្រាម

[2] ១កេសតូច ២៤កញ្ចប់

[3] ម្សៅមីគីឡូ មិនមែនម្សៅកញ្ចប់

[4] តម្លៃជាទូទៅ ៤៧% ខ្ពស់ជាងសាច់មាន់កសិកម្ម,មាន់បោចរោមរួច

[5] មាន់ទាំងមូល ពុំមែនជាបំណែកសាច់នោះទេ, មាន់បោចរោមរួច, មាន់កសិដ្ឋាន

ថ្ងៃទី ខែ ឆ្នាំ..... ..... ព.ស.២៥.....

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០.....

អ្នកធ្វើរបាយការណ៍